ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
ខេត្តកណ្តាល ថ្ងៃទី០៥ ខែ កញ្ញា ឆ្នាំ២០២២
ក្រឡាបញ្ជី
[redacted]

សាលាដំបូងខេត្តកណ្តាល

សំណុំរឿងព្រហ្មទណ្ឌលេខ÷១៧៩៥ អ.ក
ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២១
សាលក្រមលេខ÷ ៧២ (ខ)
ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២២

## សាលក្រមព្រហ្មទណ្ឌ

## តាមនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តកណ្តាល

បានបើកសវនាការជាសាធារណៈ នៅសាលាដំបូងខេត្តកណ្តាល
នាថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២២ វេលាម៉ោងប្រាំបី និងសាមសិបនាទីព្រឹក និងប្រកាសសាលក្រម
នៅថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២២ ដែលមានសមាសភាពដូចតទៅ÷

### ក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ប្រធានក្រុមប្រឹក្សាជំនុំជម្រះនៃសាលាដំបូងខេត្តកណ្តាល
លោក ចៅក្រមប្រឹក្សានៃសាលាដំបូងខេត្តកណ្តាល
លោក ចៅក្រមប្រឹក្សានៃសាលាដំបូងខេត្តកណ្តាល

### តំណាងអយ្យការ

លោក [redacted] ជាព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តកណ្តាល

### ក្រឡាបញ្ជីសវនាការ

លោក [redacted] ជាក្រឡាបញ្ជី នៃសាលាដំបូងខេត្តកណ្តាល

### ដើម្បីជំនុំជម្រះ

លើសំណុំរឿងព្រហ្មទណ្ឌលេខ១៧៩៥ អ.ក ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២១ មានជនជាប់ចោទ÷

១.ឈ្មោះ [redacted] សុវណ្ណារាជ ភេទប្រុស កើតឆ្នាំ១៩៩៤ (អាយុ២៨ឆ្នាំ) ជនជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរ បើកបរម៉ូតូឌុប កិរិតវប្បធម៌ ថ្នាក់ទី៩ ទីកន្លែងកំណើតនៅភូ[redacted] ខេត្តកណ្តាល និងទីលំនៅបច្ចុប្បន្ននៅភូ[redacted] ខេត្តកណ្តាល ឪពុកឈ្មោះ [redacted] រិន (រស់) ម្តាយឈ្មោះ [redacted] សារីម (រស់) ប្រពន្ធឈ្មោះ [redacted] ស្រីនាង (រស់) មានកូន០៣នាក់ ជានីតិជន ទោសពីមុន ធ្លាប់ជាប់ពន្ធនាគារពីបទ÷ រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន ។ (ឃុំខ្លួននៅថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២១)

២.ឈ្មោះ [redacted] ចិន្តា ភេទប្រុស កើតឆ្នាំ១៩៨០ (អាយុ៤២ឆ្នាំ) ជនជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរ កសិករ ទីកន្លែងកំណើតនៅភូ[redacted] ខេត្តកណ្តាល និងទីលំនៅ

បច្ចុប្បន្ននៅភូ[redacted] ខេត្តកណ្តាល ឪពុកឈ្មោះ [redacted]រឿង (រស់) ម្តាយឈ្មោះ [redacted]សារួន (រស់) ជានីតិជន ទោសពីមុនគ្មាន។ (គេចខ្លួន)

ត្រូវជាប់ចោទពីបទ÷ អំពើលួច (មានស្ថានទម្ងន់ទោស) ប្រព្រឹត្តនៅភូមិឈើទាល ឃុំស្វាយរមៀត ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល កាលពីថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២១ បទល្មើសដែលមានចែងតាមបញ្ញត្តិមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

-បានឃើញ ដីកាដំណោះស្រាយលេខ÷៣៤៦ ដកដស ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្តាល ។

-បានឃើញ ដីកាចាត់តាំងចៅជំនុំជម្រះលេខ÷៣៩៧ ដកចត/២២ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ ២០២២ របស់ប្រធានសាលាដំបូងខេត្តកណ្តាល ។

**អង្គហេតុដែលថ្លឹងមកតុលាការមានដូចតទៅ ÷**

កាលពីថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២១ វេលាម៉ោង០២ និង០០នាទី រំលងអាធ្រាត្រ ស្ថិតនៅភូមិឈើទាល ឃុំស្វាយរមៀត ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល មានជនជាប់ចោទឈ្មោះ [redacted] ចិន្តា បានជិះម៉ូតូម៉ាកហុងដាឌ្រីម C១២៥ ពណ៌ខ្មៅ ពាក់ស្លាកលេខ ភ្នំពេញ 1AW-0968 ចូលទៅកាត់របងសំណាញ់ដែកនៅចំហៀងផ្ទះរបស់ជនរងគ្រោះឈ្មោះ [redacted] សីម៉ា រួចឡើងទៅលើផ្ទះគាត់សោទ្វាចូលលួចយកធុងប្រព័ន្ធកំព្យូទ័រចំនួន០១ (មួយ) គ្រឿង, មិចស័រចំនួន០១ (មួយ), ធុងបាសចំនួន០៤ (បួន), ខ្សែភ្លើងចំនួន០៥ (ប្រាំ) ដុំ និងជើងទម្រសម្រាប់ច្រៀងចំនួន០១ (មួយ) រួចជនជាប់ចោទបានចងសម្ភារៈដាក់លើម៉ូតូបណ្តើរទៅដល់ផ្ទះរបស់ឈ្មោះ [redacted] តូ ស្រាប់តែម៉ូតូរបស់ជនជាប់ចោទក៏ដួលទៅលើដី ទើបឈ្មោះ [redacted] តូ ភ្ញាក់ដឹងខ្លួនចេញមកមើល ពេលនោះជនជាប់ចោទបានខ្ចីទូរស័ព្ទរបស់ឈ្មោះ [redacted] តូ តេហៅជនជាប់ចោទឈ្មោះ រិន សុវណ្ណារាជ ឲ្យមកជួយយក។ បន្ទាប់មកជនជាប់ចោទឈ្មោះ សោ ចិន្តា បានឈប់ចាំជនជាប់ចោទឈ្មោះ [redacted]សុវណ្ណារាជ រហូតដល់ម៉ោង០៤ និង៣០ នាទីទៀបភ្លឺ ដោយឈ្មោះ [redacted] តូ មានការសង្ស័យ ក៏បានតេទូរស័ព្ទរាយការណ៍ជូនសមត្ថកិច្ចនគរបាលប៉ុស្តិ៍ស្វាយរមៀត ហើយពេលដែលសមត្ថកិច្ចចុះទៅដល់ ជនជាប់ចោទឈ្មោះ [redacted] ចិន្តា បានរត់គេចខ្លួនបាត់ ដោយបន្សល់ទុកម៉ូតូ និងសម្ភារៈដែលលួចបាន។ លុះដល់ម៉ោង០៥ និង៣០ នាទី ជនជាប់ចោទឈ្មោ[redacted] សុវណ្ណារាជ បានជិះម៉ូតូម៉ាកសង់ការ៉េ ពណ៌ស្លាទុំ ពាក់ស្លាកលេខ 1G-0239 ទៅជួយយកសម្ភារៈដែលលួចបាននោះ តែក៏ជួបសមត្ថកិច្ចប៉ុស្តិ៍នគរបាលស្វាយរមៀត រួចឃាត់ខ្លួនជនជាប់ចោទឈ្មោះ [redacted] សុវណ្ណារាជ មកកាន់អធិការដ្ឋាននគរបាលស្រុកខ្សាច់កណ្តាលតែម្តង។

**នាពេលសវនាការ ÷**

១.ជនជាប់ចោទឈ្មោះ [redacted] សុវណ្ណារាជ បានឆ្លើយថា÷ នៅក្នុងរឿងនេះ ខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ឡើយ។ ខ្លួនស្គាល់ឈ្មោះ[redacted] ចិន្តា ព្រោះគាត់ត្រូវជាបងជីដូនមួយរបស់ខ្លួន។ នៅពេលកើតហេតុ ខ្ញុំបាទមិនដឹងថាឈ្មោះ [redacted] ចិន្តា លួចរបស់គេឡើយ។ សូមបញ្ជាក់ថា នៅថ្ងៃកើតហេតុ ខ្លួន



Scanned with CamScanner

និងប្រពន្ធឈ្មោះ [redacted] ស្រីនាង បានចេញរើសអេតចាយជាមួយគ្នា ។ លុះដល់ម៉ោងប្រហែលជាជាងបីទៀបភ្លឺ ឈ្មោះ [redacted] ចិន្តា បានខលទូរស័ព្ទមកខ្លួន ដោយឲ្យខ្លួនទៅឌុបគាត់ទៅផ្ទះវិញផង គាត់នៅវត្តឈើទាល ។ បន្ទាប់មក ខ្លួនបានឌុបប្រពន្ធទៅផ្ទះរួច នៅវេលាម៉ោងប្រហែលជាជាងបួនទៀបភ្លឺ ខ្លួនក៏បានជិះម៉ូតូទៅតាមទីតាំងដែលឈ្មោះ [redacted] ចិន្តា ប្រាប់។ ប៉ុន្តែ នៅពេលដែលខ្លួនជិះម៉ូតូទៅតាមផ្លូវ ក៏ឃើញមានម៉ូតូឌួល ហើយមនុស្សអ៊ូរអរ និងមានសមត្ថកិច្ចនៅកន្លែងនោះផងដែរ ហើយពេលនោះសមត្ថកិច្ចក៏បានធ្វើការសាកសួរខ្លួនថា មានស្គាល់ម៉ូតូដែលឌួលនោះឬទេ? ខ្លួនបានឆ្លើយថាស្គាល់ ម៉ូតូនោះគឺជារបស់បងជីដូនមួយខ្លួនឈ្មោះ [redacted] ចិន្តា។ បន្ទាប់មក សមត្ថកិច្ចក៏បានធ្វើការឃាត់រូបខ្លួនមកអធិការដ្ឋាននគរបាលស្រុកខ្សាច់កណ្តាលតែម្តង។ ខ្លួនមិនធ្លាប់ស្គាល់ឈ្មោះ [redacted] សីម៉ា ឡើយ។ ហើយខ្លួនក៏មិនធ្លាប់លួចគេដែរ។ ខ្លួនធ្លាប់ជាប់ពន្ធនាគារម្តងជាប់ពាក់ព័ន្ធនឹងរឿងរក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន។ សូមបញ្ជាក់ថា ខ្លួនមានមុខរបរជាកម្មករសំណង់នៅពេលថ្ងៃ និងនៅពេលយប់ខ្លួនគឺជាអ្នករើសអេតចាយ ។

២.ក្រឡាបញ្ជីអានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សីម៉ា បានឆ្លើយថា÷ ខ្លួនសូមរក្សាចម្លើយនៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ កាលពីថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២១ ទុកជាបានការដដែល។ កាលពីឆ្នាំ២០១៧ ខ្លួនបានទិញដីមួយកន្លែងនៅភូមិឈើទាល ឃុំស្វាយរមៀត ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ហើយធ្វើផ្ទះថ្ម មានទំហំ៦ម៉ែត្រ គុណ១០ម៉ែត្រ ប្រក់ក្បឿង និងបានបើកស្ទូឌីយោសម្រាប់ថតបទចម្រៀង ដែលមានឧបករណ៍ជាច្រើន ហើយយូរៗទើបខ្លួនមកម្តង ដោយពុំមានអ្នកនៅចាំនោះទេ។ លុះនៅថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២១ វេលាម៉ោង០៦ ព្រឹក ឈ្មោះ [redacted] ភេទស្រី រស់នៅភូមិឈើទាល ឃុំស្វាយរមៀត ដែលមានផ្ទះនៅទល់មុខផ្ទះរបស់ខ្លួន បានតេទូរស័ព្ទប្រាប់ខ្លួនថា មានចោរគាស់ផ្ទះខ្លួនលួចយកសម្ភារៈអស់ជាច្រើន ឥឡូវកម្លាំងនគរបាលប៉ុស្តិ៍ស្វាយរមៀតចាប់បានចោរ និងបានដកហូតសម្ភារៈមួយចំនួនទៀត។ ពេលលឺដូច្នេះ ខ្លួនក៏ចេញពីផ្ទះប្អូនខ្លួននៅឃុំព្រែកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្តាល ទៅពិនិត្យផ្ទះរបស់ខ្លួននៅភូមិឈើទាល ឃុំស្វាយរមៀត បានឃើញស្នាមកាត់លួសសំណាញ់របងចំហៀងខាងត្បូងក្បែរបន្ទប់ទឹកមួយកន្លែង និងសោទ្វារខាងមុខរបូតចេញពីមេសោ ពេលចូលពិនិត្យក្នុងបន្ទប់ស្ទូឌីយោ ឃើញបាត់ធុងបាស់ចំនួន០៧ (ប្រាំពីរ) គ្រាប់, មិចស័រចំនួន០១ (មួយ) គ្រឿង, កំព្យូទ័រចំនួន០២ (ពីរ) គ្រឿង, អកចំនួន០១ (មួយ) គ្រឿង, ម៉ាស៊ីនបញ្ចាំងស្លាយចំនួន០១ (មួយ) គ្រឿង, អាំងម៉ូនីទប់ភ្លើងចំនួន០២ (ពីរ) គ្រឿង, ជើងទ្រក្បាលមេក្រូចំនួន០១ (មួយ), ក្បាលមេក្រូចំនួន០១ (មួយ) គ្រឿង, និងខ្សែភ្លើងមួយចំនួនសរុបជាទឹកប្រាក់ប្រហែលចំនួន៣,០០០ (បីពាន់) ដុល្លារអាមេរិក។ បន្ទាប់មកខ្លួនបានទៅប៉ុស្តិ៍នគរបាលរដ្ឋបាលស្វាយរមៀត ក៏បានឃើញជនជាប់ចោទម្នាក់មិនស្គាល់ឈ្មោះដែលសមត្ថកិច្ចឃាត់ខ្លួនបាន រួមទាំងវត្ថុតាងដែលជារបស់ខ្លួនមានដូចជា ធុងបាស់ចំនួន០៤ (បួន) គ្រាប់, មិចស័រចំនួន០១ (មួយ) គ្រឿង, ជើងទ្រក្បាលមេក្រូចំនួន០១ (មួយ) និងខ្សែភ្លើងចំនួន០៥ (ប្រាំ) ដុំ ប៉ុន្តែនៅបាត់ធុងបាស់ចំនួន០៣ (បី) គ្រាប់, ក្បាលមេក្រូចំនួន០១ (មួយ)គ្រឿង, ម៉ូនី

ទ័រចំនួន០២ (ពីរ) គ្រឿង, ធុងប្រពន្ធកំព្យូទ័រចំនួន០១ (មួយ)គ្រឿង, និងអកចំនួន០១ (មួយ) គ្រឿង។ ចំពោះសម្ភារៈដែលចោរលួចនោះ គឺខ្លួនបានទទួលវិញខ្លះហើយ នៅខ្វះតែធុងបាស់ចំនួន០៣(បី) គ្រាប់, ក្បាលមេក្រូច្រៀងចំនួន០១ (មួយ) គ្រឿង, ម៉ូនីទ័រចំនួន០២ (ពីរ) គ្រឿង, ធុងប្រព័ន្ធកំព្យូទ័រចំនួន០១ (មួយ) គ្រឿង និងអកចំនួន០១ (មួយ) គ្រឿង ។ សូមសំណូមពរ សុំទាមទារសំណងថ្លៃសម្ភារៈដែលបានបាត់សរុបចំនួន១,០០០(មួយពាន់) ដុល្លារអាមេរិក។

៣.ក្រឡាបញ្ជីអានចម្លើយសាក្សីឈ្មោះ [redacted]តួ បានឆ្លើយថា÷ នៅថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២១ វេលាម៉ោង០២ និង៣០ នាទីរំលងអធ្រាត្រ ខណៈពេលខ្លួនកំពុងតែដេកក៏ឮសំឡេងដួលម៉ូតូ និងឮសូរសម្លេងឆ្កែព្រុះយ៉ាងខ្លាំងនៅមុខផ្ទះរបស់ខ្លួន ភ្លាមនោះខ្លួនក៏បើកទ្វារផ្ទះដើរចេញមកមើល ស្រាប់តែឃើញមានមនុស្សប្រុសម្នាក់មិនស្គាល់ឈ្មោះ ពាក់អាវយឺតដៃខ្លីពណ៌ខ្មៅ ស្លៀកខោសាច់ក្រណាត់ជើងវែងពណ៌ខ្មៅ ពាក់ម៉ាស ពាក់មួកការ៉េពណ៌ខ្មៅ ដួលម៉ូតូនៅមុខផ្ទះខ្លួន ឃើញមានធុងខ្សែភ្លើង និងសម្ភារៈមួយចំនួនទៀតដែលខ្លួនមិនស្គាល់ រួមជាមួយម៉ូតូម៉ាកហុងដាឌ្រីម សេ១២៥ មិនចាំសេរី មិនចាំស្លាកលេខពណ៌ខ្មៅ ហើយមនុស្សប្រុសនោះបានហៅខ្លួនឱ្យជួយលើកម៉ូតូ និងធុងបាសដាក់លើម៉ូតូ ហើយមនុស្សប្រុសនោះបានឱ្យខ្លួនជួយរុញម៉ូតូបានចម្ងាយប្រហែល៥០ម៉ែត្រពីមុខផ្ទះរបស់ខ្លួន។ បន្ទាប់មកមនុស្សប្រុសនោះបានខ្ចីទូរស័ព្ទរបស់ខ្លួនតេ ប៉ុន្តែខ្លួនមិនដឹងថាខ្ចីទូរស័ព្ទខ្លួនតេទៅពីណាគេទេ។ បន្ទាប់ពីតេរួចហើយបុរសម្នាក់នោះបានអោយទូរស័ព្ទមកខ្លួនវិញ ដោយមានការសង្ស័យខ្លួនក៏ទូរស័ព្ទប្រាប់សមត្ថកិច្ចប៉ុស្តិ៍ស្វាយរមៀត។ ភ្លាមៗនោះ សមត្ថកិច្ចបានចុះមកដល់ ស្រាប់តែប្រុសម្នាក់មិនស្គាល់ឈ្មោះនោះបានរត់គេចខ្លួនបាត់ទៅ បន្ទាប់មកសមត្ថកិច្ចនគរបាលប៉ុស្តិ៍ស្វាយរមៀតក៏យកម៉ូតូ ធុងបាស និងសម្ភារៈមួយចំនួនទៀតទៅកាន់ប៉ុស្តិ៍នគរបាលស្វាយរមៀតតែម្តង។ លុះមួយសន្ទុះក្រោយមកទូរស័ព្ទរបស់ខ្លួនក៏បានរោទ៍ ហើយខ្លួនក៏បានយកទូរស័ព្ទមកចុចទទួលក៏ឮសំឡេងមនុស្សប្រុសនិយាយ ប៉ុន្តែខ្លួនមិនដែលស្គាល់លេខទូរស័ព្ទនេះទេ ហើយនិយាយថា មកដល់វត្តឈើទាលហើយ ទើបខ្លួនគិតថាប្រហែលជាគ្នារបស់មនុស្សប្រុសម្នាក់ដែលមិនស្គាល់ឈ្មោះបានខ្ចីទូរស័ព្ទខ្លួននិយាយមុននេះហើយ ទើបខ្លួនប្រាប់ឱ្យជិះមកទៀតមក។ លុះជិះម៉ូតូទៅដល់មុខវត្តវិហារពេជ្រ ក៏បានតេទូរស័ព្ទមកខ្លួនម្តងទៀតនិយាយថា នៅណា ខ្លួនក៏ប្រាប់ថា នៅផ្លូវកែង ពេលនោះខ្លួនក៏បានសួរថា បងឯងនៅណា បន្ទាប់មកមនុស្សប្រុសនោះឆ្លើយថា នៅមុខវត្តវិហារពេជ្រ ខ្លួនប្រាប់ថាហួសហើយឱ្យជិះបកក្រោយវិញ លុះពេលជិះមកដល់សមត្ថកិច្ចនគរបាលក៏ធ្វើការឃាត់ខ្លួនបញ្ជូនទៅប៉ុស្តិ៍នគរបាលស្វាយរមៀត តែម្តង។

**៤.តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំ÷** ក្រោយពីបានស្តាប់ការសួរដេញដោលនាពេលសវនាការរួចមក តាមរយៈចម្លើយរបស់ជនជាប់ចោទ និងភស្តុតាងផ្សេងៗនៅក្នុងសំណុំរឿង ឃើញថាតំណាងអយ្យការនៅតែតម្កល់ការចោទប្រកាន់ដូចនៅក្នុងដីកាសន្និដ្ឋានស្ថាពរលេខ៣១១ ដកសព ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២២ ទុកជាបានការដដែល និងសុំឱ្យតុលាការពិចារណាតាមច្បាប់ ។

៥. មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានថា÷ ក្រោយពីបានបញ្ចប់ការសួរដេញដោលនាពេលសវនាការរួចមក ឃើញថា កូនក្តីខ្ញុំបាទឈ្មោះ[redacted]សុវណ្ណារាជ បានឆ្លើយបដិសេធថា ខ្លួនមិនបានចូលរួមលួច ឬប្រព្រឹត្តជាមួយឈ្មោះ [redacted] ចិន្តា នោះទេ នៅគ្រប់ដំណាក់កាលទាំងអស់។ ចំណុចមួយទៀត គឺថា នៅក្នុងរឿងនេះ ពុំមានសាក្សីណាមួយបានឃើញ កូនក្តីខ្ញុំបាទឈ្មោះ[redacted]សុវណ្ណារាជ ធ្វើសកម្មភាពលួចជាមួយនឹងឈ្មោះ សោ ចិន្តា នោះទេ សូម្បីតែសាក្សីឈ្មោះ ឡុង តូ ក៏មិនបានឃើញដែរ។ ចំណុចទាំងអស់នេះ អាចបញ្ជាក់បានថា មិនមានភស្តុតាងគ្រប់គ្រាន់ដាក់បន្ទុកមកលើកូនក្តីខ្ញុំបាទឈ្មោះ [redacted] សុវណ្ណារាជ ភេទប្រុស ពីបទ អំពើលួច (មានស្ថានទម្ងន់ទោស) ដែលមានចែងតាមបញ្ញត្តិមាត្រា៣៥៣, ៣៥៧ នៃក្រមព្រហ្មទណ្ឌ ឡើយ។ ហេតុនេះ ការចោទប្រកាន់មកលើកូនក្តីខ្ញុំបាទឈ្មោះ [redacted]សុវណ្ណារាជ គឺនៅមានវិមតិសង្ស័យនៅឡើយ។ ផ្អែកតាមមាត្រា៣៨ នៃរដ្ឋធម្មនុញ្ញ ចែងថាវិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ។ ហេតុដូច្នេះ ខ្ញុំបាទស្នើសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះសម្រេចឱ្យកូនក្តីខ្ញុំបាទឈ្មោះ [redacted] សុវណ្ណារាជ រួចផុតពីបទចោទប្រកាន់តាមមាត្រា៣៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ដោយឡែក ចំពោះកូនក្តីខ្លួនឈ្មោះ [redacted] ចិន្តា មិនមានសាក្សីណាមួយឃើញគាត់ប្រព្រឹត្តអំពើលួចផ្ទាល់ភ្នែកឡើយ ។ ម្យ៉ាងវិញទៀត កូនក្តីខ្ញុំបាទមិនមានវត្តមាននៅក្នុងសវនាការ ដើម្បីឆ្លើយដោះសារចំពោះការចោទប្រកាន់ឡើយ។ លើសពីនេះទៅទៀត ទាំងដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សី សុទ្ធតែពុំបានឃើញកូនក្តីខ្ញុំបាទប្រព្រឹត្តដូចបទចោទប្រកាន់ឡើយ។ ហេតុនេះ ខ្ញុំបាទស្នើសុំឱ្យតុលាការសម្រេចឱ្យកូនក្តីខ្ញុំបាទឈ្មោះ [redacted] ចិន្តា រួចផុតពីបទចោទប្រកាន់តាមមាត្រា៣៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

- ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទឈ្មោះ[redacted]សុវណ្ណារាជ
- ក្រោយពីបានស្តាប់ក្រឡាបញ្ជីអានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី
- ក្រោយពីបានស្តាប់ចម្លើយរបស់សាក្សីឈ្មោះ[redacted] តូ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ
- ក្រោពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ
- ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ[redacted] សុវណ្ណារាជ
- ក្រោយពីបានពិនិត្យលើភស្តុតាងផ្សេងៗនៅក្នុងសំណុំរឿង
- ក្រោយពីបានពិនិត្យ និងពិភាក្សាក្នុងក្រុមប្រឹក្សាត្រឹមត្រូវតាមច្បាប់ហើយ។

## សំអាងហេតុ

១. យល់ឃើញថា កាលពីថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២១ វេលាម៉ោង០២ និង០០នាទី វិលងអាជ្រោត្រ ស្ថិតនៅភូមិឈើទាល ឃុំស្វាយរមៀត ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ពិតជាមានករណី អំពើលួច (មានស្ថានទម្ងន់ទោស) ប្រព្រឹត្តដោយមានជនជាប់ចោទឈ្មោះ [redacted] ចិន្តា បានជិះម៉ូតូម៉ាក ហុងដាឌ្រីម C១២៥ ពណ៌ខ្មៅ ពាក់ស្លាកលេខ ភ្នំពេញ 1AW-0968 ចូលទៅកាត់របងសំណាញ់ដែកនៅចំហៀងផ្ទះរបស់ជនរងគ្រោះឈ្មោះ [redacted] សីម៉ា រួចឡើងទៅលើផ្ទះគាត់សោទ្វារចូលលួចយកធុងប្រព័ន្ធកំព្យូទ័រចំនួន



Scanned with CamScanner

០១ (មួយ) គ្រឿង, មិចស័រចំនួន០១ (មួយ), ធុងបាសចំនួន០៤ (បួន), ខ្សែភ្លើងចំនួន០៥ (ប្រាំ)ដុំ និងជើងទម្រសម្រាប់ច្រៀងចំនួន០១ (មួយ) រួចជនជាប់ចោទបានចងសម្ភារៈដាក់លើម៉ូតូបណ្ដើរទៅដល់មុខផ្ទះរបស់ឈ្មោះ [redacted] តូ ស្រាប់តែម៉ូតូរបស់ជនជាប់ចោទក៏ដួលទៅលើដី ទើបឈ្មោះ [redacted] តូ ភ្ញាក់ដឹងខ្លួនចេញមកមើល ពេលនោះជនជាប់ចោទបានខ្ចីទូរស័ព្ទរបស់ឈ្មោះ [redacted] តូ តេហៅជនជាប់ចោទឈ្មោះ [redacted] សុវណ្ណារាជ ឱ្យមកជួយយក។ បន្ទាប់មកជនជាប់ចោទឈ្មោះ [redacted] ចិន្តា បានឈប់ចាំជនជាប់ចោទឈ្មោះ [redacted] សុវណ្ណារាជ រហូតដល់ម៉ោង០៤ និង៣០ នាទីទៀបភ្លឺ ដោយឈ្មោះ [redacted] តូ មានការសង្ស័យ ក៏បានតេទូរស័ព្ទរាយការណ៍ជូនសមត្ថកិច្ចនគរបាលប៉ុស្តិ៍ស្វាយរមៀត ហើយពេលដែលសមត្ថកិច្ចចុះទៅដល់ ជនជាប់ចោទឈ្មោះ [redacted] ចិន្តា បានរត់គេចខ្លួនបាត់ ដោយបន្សល់ទុកម៉ូតូ និងសម្ភារៈដែលលួចបាន។ លុះដល់ម៉ោង០៥ និង៣០ នាទី ជនជាប់ចោទឈ្មោះ [redacted] សុវណ្ណារាជ បានជិះម៉ូតូម៉ាក សង់ការ៉េ ពណ៌ស្លាទុំ ពាក់ស្លាកលេខ 1G-0239 ទៅជួយយកសម្ភារៈដែលលួចបាននោះ តែក៏ជួបសមត្ថកិច្ចប៉ុស្តិ៍នគរបាលស្វាយរមៀត រួចឃាត់ខ្លួនជនជាប់ចោទឈ្មោះ [redacted] សុវណ្ណារាជ មកកាន់អធិការដ្ឋាននគរបាលស្រុកខ្សាច់កណ្ដាលតែម្ដង។

២. យល់ឃើញថា តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] សុវណ្ណារាជ បានឆ្លើយថា៖ នៅក្នុងរឿងនេះ ខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ឡើយ។ ខ្លួនស្គាល់ឈ្មោះ [redacted] ចិន្តា ព្រោះគាត់ត្រូវជាបងជីដូនមួយរបស់ខ្លួន។ នៅពេលកើតហេតុ ខ្ញុំបាទមិនដឹងថាឈ្មោះ [redacted] ចិន្តា លួចរបស់គេឡើយ។ សូមបញ្ជាក់ថា នៅថ្ងៃកើតហេតុ ខ្លួន និងប្រពន្ធឈ្មោះ [redacted] ស្រីនាង បានចេញរើសអេតចាយជាមួយគ្នា ។ លុះដល់ម៉ោងប្រហែលជាជាងបីទៀបភ្លឺ ឈ្មោះ [redacted] ចិន្តា បានខលទូរស័ព្ទមកខ្លួន ដោយឱ្យខ្លួនទៅឌុបគាត់ទៅផ្ទះវិញផង គាត់នៅវត្តឈើទាល ។ បន្ទាប់មក ខ្លួនបានឌុបប្រពន្ធទៅផ្ទះរួច នៅវេលាម៉ោងប្រហែលជាជាងបួនទៀបភ្លឺ ខ្លួនក៏បានជិះម៉ូតូទៅតាមទីតាំងដែលឈ្មោះ [redacted] ចិន្តា ប្រាប់។ ប៉ុន្តែ នៅពេលដែលខ្លួនជិះម៉ូតូទៅតាមផ្លូវ ក៏ឃើញមានម៉ូតូឌួល ហើយមនុស្សអ៊ូរអរ និងមានសមត្ថកិច្ចនៅកន្លែងនោះផងដែរ ហើយពេលនោះ សមត្ថកិច្ចក៏បានធ្វើការសាកសួរខ្លួនថា មានស្គាល់ម៉ូតូដែលឌួលនោះឬទេ? ខ្លួនបានឆ្លើយថាស្គាល់ ម៉ូតូនោះគឺជារបស់បងជីដូនមួយខ្លួនឈ្មោះ [redacted] ចិន្តា។ បន្ទាប់មក សមត្ថកិច្ចក៏បានធ្វើការឃាត់រូបខ្លួនមកអធិការដ្ឋាននគរបាលស្រុកខ្សាច់កណ្ដាលតែម្ដង។ ខ្លួនមិនធ្លាប់ស្គាល់ឈ្មោះ [redacted] សីម៉ា ឡើយ។ ហើយខ្លួនក៏មិនធ្លាប់លួចគេដែរ។ ខ្លួនធ្លាប់ជាប់ពន្ធនាគារម្ដងជាប់ពាក់ព័ន្ធនឹងរឿងរក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន។ សូមបញ្ជាក់ថា ខ្លួនមានមុខរបរជាកម្មករសំណង់នៅពេលថ្ងៃ និងនៅពេលយប់ខ្លួនគឺជាអ្នករើសអេតចាយ ។

៣. យល់ឃើញថា តាមចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] សីម៉ា បានឆ្លើយថា៖ ខ្លួនសូមរក្សាចម្លើយនៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ កាលពីថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២១ ទុកជាបានការដដែល។ កាលពីឆ្នាំ២០១៧ ខ្លួនបានទិញដីមួយកន្លែងនៅភូមិឈើទាល ឃុំស្វាយរមៀត ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល ហើយធ្វើផ្ទះថ្ម មានទំហំ៦ម៉ែត្រ គុណ១០ម៉ែត្រ ប្រក់ក្បឿង និងបានបើក

ស្ទូឌីយោសម្រាប់ថតបទចម្រៀង ដែលមានឧបករណ៍ជាច្រើន ហើយយូរៗទើបខ្លួនមកម្តង ដោយពុំមានអ្នកនៅចាំនោះទេ។ លុះនៅថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២១ វេលាម៉ោង០៦ ព្រឹក ឈ្មោះ [redacted] ភេទស្រី រស់នៅភូមិឈើទាល ឃុំស្វាយរមៀត ដែលមានផ្ទះនៅទល់មុខផ្ទះរបស់ខ្លួន បានតេទូរស័ព្ទប្រាប់ខ្លួនថា មានចោរគាស់ផ្ទះខ្លួនលួចយកសម្ភារៈអស់ជាច្រើន ឥឡូវកម្លាំងនគរបាលប៉ុស្តិ៍ស្វាយរមៀតចាប់បានចោរ និងបានដកហូតសម្ភារៈមួយចំនួនទៀត។ ពេលលឺដូច្នេះ ខ្លួនក៏ចេញពីផ្ទះប្អូនខ្លួននៅឃុំព្រែកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្តាល ទៅពិនិត្យផ្ទះរបស់ខ្លួននៅភូមិឈើទាល ឃុំស្វាយរមៀត បានឃើញស្នាមកាត់លួសសំណាញ់របងចំហៀងខាងត្បូងក្បែរបន្ទប់ទឹកមួយកន្លែង និងសោទ្វារខាងមុខរបូតចេញពីមេសោ ពេលចូលពិនិត្យក្នុងបន្ទប់ស្ទូឌីយោ ឃើញបាត់ធុងបាស់ចំនួន០៧ (ប្រាំពីរ) គ្រាប់, មិចស័រចំនួន០១ (មួយ) គ្រឿង, កំព្យូទ័រចំនួន០២ (ពីរ) គ្រឿង, អកចំនួន០១ (មួយ) គ្រឿង, ម៉ាស៊ីនបញ្ចាំងស្លាយចំនួន ០១ (មួយ) គ្រឿង, អាំងម៉ូនីទប់ភ្លើងចំនួន០២ (ពីរ) គ្រឿង, ជើងទ្រក្បាលមេក្រូចំនួន០១ (មួយ), ក្បាលមេក្រូចំនួន០១ (មួយ) គ្រឿង, និងខ្សែភ្លើងមួយចំនួនសរុបជាទឹកប្រាក់ប្រហែលចំនួន៣,០០០ (បីពាន់) ដុល្លារអាមេរិក។ បន្ទាប់មកខ្លួនបានទៅប៉ុស្តិ៍នគរបាលរដ្ឋបាលស្វាយរមៀត ក៏បានឃើញជនជាប់ចោទម្នាក់មិនស្គាល់ឈ្មោះដែលសមត្ថកិច្ចឃាត់ខ្លួនបាន រួមទាំងវត្ថុតាងដែលជារបស់ខ្លួនមានដូចជា ធុងបាស់ចំនួន០៤ (បួន) គ្រាប់, មិចស័រចំនួន០១ (មួយ) គ្រឿង, ជើងទ្រក្បាលមេក្រូចំនួន០១ (មួយ) និងខ្សែភ្លើងចំនួន០៥ (ប្រាំ) ដុំ ប៉ុន្តែនៅបាត់ធុងបាស់ចំនួន០៣ (បី) គ្រាប់, ក្បាលមេក្រូចំនួន០១ (មួយ)គ្រឿង, ម៉ូនីទ័រចំនួន០២ (ពីរ) គ្រឿង, ធុងប្រពន្ធកំព្យូទ័រចំនួន០១ (មួយ)គ្រឿង, និងអកចំនួន០១ (មួយ) គ្រឿង។ ចំពោះសម្ភារៈដែលចោរលួចនោះ គឺខ្លួនបានទទួលវិញខ្លះហើយ នៅខ្វះតែធុងបាស់ចំនួន០៣ (បី) គ្រាប់, ក្បាលមេក្រូច្រៀងចំនួន០១ (មួយ) គ្រឿង, ម៉ូនីទ័រចំនួន០២ (ពីរ) គ្រឿង, ធុងប្រព័ន្ធកំព្យូទ័រចំនួន០១ (មួយ) គ្រឿង និងអកចំនួន០១ (មួយ) គ្រឿង ។ សូមសំណូមពរ សុំទាមទារសំណងថ្លៃសម្ភារៈដែលបានបាត់សរុបចំនួន១,០០០ (មួយពាន់) ដុល្លារអាមេរិក។

៤. យល់ឃើញថា តាមចម្លើយរបស់សាក្សីឈ្មោះ [redacted] បានឆ្លើយថា÷ នៅថ្ងៃទី២៥ ខែតុលា ឆ្នាំ ២០២១ វេលាម៉ោង០២ និង៣០ នាទីរំលងអធ្រាត្រ ខណៈពេលខ្លួនកំពុងតែដេកក៏ឮសំឡេងដួលម៉ូតូ និងឮស្នូរសម្លេងឆ្កែព្រុះយ៉ាងខ្លាំងនៅមុខផ្ទះរបស់ខ្លួន ភ្លាមនោះខ្លួនក៏បើកទ្វារផ្ទះដើរចេញមកមើល ស្រាប់តែឃើញមានមនុស្សប្រុសម្នាក់មិនស្គាល់ឈ្មោះ ពាក់អាវយឺតដៃខ្លីពណ៌ខ្មៅ ស្លៀកខោសាច់ក្រណាត់ជើងវែងពណ៌ខ្មៅ ពាក់ម៉ាស ពាក់មួកកាប៉េពណ៌ខ្មៅ ដួលម៉ូតូនៅមុខផ្ទះខ្លួន ឃើញមានធុងខ្សែភ្លើង និងសម្ភារៈមួយចំនួនទៀតដែលខ្លួនមិនស្គាល់ រួមជាមួយម៉ូតូម៉ាកហុងដាឌ្រីម សេ១២៥ មិនចាំស៊េរី មិនចាំស្លាកលេខ ពណ៌ខ្មៅ ហើយមនុស្សប្រុសនោះបានហៅខ្លួនឲ្យជួយលើកម៉ូតូ និងធុងបាសដាក់លើម៉ូតូ ហើយមនុស្សប្រុសនោះបានឲ្យខ្លួនជួយរុញម៉ូតូបានចម្ងាយប្រហែល៥០ម៉ែត្រពីមុខផ្ទះរបស់ខ្លួន។ បន្ទាប់មកមនុស្សប្រុសនោះបានខ្ចីទូរស័ព្ទរបស់ខ្លួនតេ ប៉ុន្តែខ្លួនមិនដឹងថាខ្ចីទូរស័ព្ទខ្លួនតេទៅពីណាគេទេ។ បន្ទាប់ពីតេរួចហើយបុរសម្នាក់នោះបានអោយទូរស័ព្ទមកខ្លួនវិញ ដោយមានការសង្ស័យខ្លួនក៏ទូរស័ព្ទ

ប្រាប់សមត្ថកិច្ចប៉ុស្តិ៍ស្វាយរមៀត។ ភ្លាមៗនោះ សមត្ថកិច្ចបានចុះមកដល់ ស្រាប់តែប្រុសម្នាក់មិនស្គាល់ឈ្មោះនោះបានរត់គេចខ្លួនបាត់ទៅ បន្ទាប់មកសមត្ថកិច្ចនគរបាលប៉ុស្តិ៍ស្វាយរមៀតក៏យកម៉ូតូ ធុងបាស និងសម្ភារៈមួយចំនួនទៀតទៅកាន់ប៉ុស្តិ៍នគរបាលស្វាយរមៀតតែម្តង។ លុះមួយសន្ទុះក្រោយមកទូរស័ព្ទរបស់ខ្លួនក៏បានរោទ៍ ហើយខ្លួនក៏បានយកទូរស័ព្ទមកចុចទទួលក៏ឮសំឡេងមនុស្សប្រុសនិយាយ ប៉ុន្តែខ្លួនមិនដែលស្គាល់លេខទូរស័ព្ទនេះទេ ហើយនិយាយថា មកដល់វត្តឈើទាលហើយ ទើបខ្លួនគិតថាប្រហែលជាគ្នារបស់មនុស្សប្រុសម្នាក់ដែលមិនស្គាល់ឈ្មោះបានខ្ចីទូរស័ព្ទខ្លួននិយាយមុននេះហើយ ទើបខ្លួនប្រាប់ឱ្យជិះមកទៀតមក។ លុះជិះម៉ូតូទៅដល់មុខវត្តវិហារពេជ្រ ក៏បានគេទូរស័ព្ទមកខ្លួនម្តងទៀតនិយាយថា នៅណា ខ្លួនក៏ប្រាប់ថា នៅផ្លូវកែង ពេលនោះខ្លួនក៏បានសួរថា បងឯងនៅណា បន្ទាប់មកមនុស្សប្រុសនោះឆ្លើយថា នៅមុខវត្តវិហារពេជ្រ ខ្លួនប្រាប់ថាហួសហើយឱ្យជិះបកក្រោយវិញ លុះពេលជិះមកដល់សមត្ថកិច្ចនគរបាលក៏ធ្វើការឃាត់ខ្លួនបញ្ជូនទៅប៉ុស្តិ៍នគរបាលស្វាយរមៀត តែម្តង។

៥. **យល់ឃើញថា** ផ្អែកតាមអង្គហេតុខាងលើ, ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] សុវណ្ណារាជ, ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សីម៉ា, ចម្លើយរបស់សាក្សីឈ្មោះ [redacted] តូ និងភស្តុតាងផ្សេងៗនៅក្នុងសំណុំរឿង អាចបញ្ជាក់បានថា ឈ្មោះ [redacted] ចិន្តា ពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់មែន។ ចំណែកឈ្មោះ [redacted] សុវណ្ណារាជ មិនបានប្រព្រឹត្តដូចការចោទប្រកាន់ឡើយ ដោយហេតុថា នៅថ្ងៃកើតហេតុ ក្រោយពេលដែលជនជាប់ចោទឈ្មោះ [redacted] ចិន្តា ធ្វើសកម្មភាពចូលទៅកាត់របងសំណាញ់ដែកនៅចំហៀងផ្ទះ និងគាស់សោទ្វារចូលទៅក្នុងផ្ទះរបស់ជនរងគ្រោះ លួចយកបានធុងប្រព័ន្ធកិព្យទ័រចំនួន០១ (មួយ) គ្រឿង, មិចស័រចំនួន០១ (មួយ), ធុងបាសចំនួន០៤ (បួន), ខ្សែភ្លើងចំនួន០៥ (ប្រាំ) ដុំ និងជើងទម្ររសម្រាប់ច្រៀងចំនួន០១ (មួយ) តែម្នាក់ឯងរួចហើយ ជនជាប់ចោទរូបនេះ ក៏បានដឹកសម្ភារៈទាំងអស់នោះចេញដោយប្រើម៉ូតូ០១គ្រឿងម៉ាក ហុងដាឌ្រីម C១២៥ ពណ៌ខ្មៅ ពាក់ស្លាកលេខ ភ្នំពេញ 1AW-0968 ចេញទៅ តែពេលដែលជនជាប់ចោទឈ្មោះ [redacted] ចិន្តា បណ្តើរម៉ូតូនោះដល់មុខផ្ទះរបស់សាក្សីឈ្មោះ [redacted] តូ ក៏បណ្តាលឱ្យដួលម៉ូតូនោះធ្វើឱ្យឈ្មោះ [redacted] តូ ភ្ញាក់ពីដំណេក និងបានចេញមកមើល ស្រាប់តែឃើញជនជាប់ចោទម្នាក់ឈ្មោះ [redacted] ចិន្តា ដួលម៉ូតូ ព្រមទាំងមានសម្ភារៈមួយចំនួនទៀតដែលដឹកជាប់ម៉ូតូ ។ ខណៈពេលនោះ ជនជាប់ចោទឈ្មោះ [redacted] ចិន្តា ក៏បានឱ្យសាក្សីឈ្មោះ [redacted] តូ ជួយរុញម៉ូតូ និងបានខ្ចីទូរស័ព្ទរបស់ឈ្មោះ [redacted] តូ ខលទៅជនជាប់ចោទឈ្មោះ [redacted] សុវណ្ណារាជ ឱ្យមកឌុបខ្លួនទៅផ្ទះ ទាំងដែលជនជាប់ចោទឈ្មោះ [redacted] សុវណ្ណារាជ កំពុងរើសអេតចាយជាមួយប្រពន្ធ ដោយពុំដឹងថាជនជាប់ចោទឈ្មោះ [redacted] ចិន្តា បានប្រព្រឹត្តអំពើលួចនោះដែរ ។ នៅពេលដែលជនជាប់ចោទឈ្មោះ [redacted] ចិន្តា និយាយទូរស័ព្ទចប់ ក៏បានប្រគល់ទូរស័ព្ទឱ្យទៅឈ្មោះ [redacted] តូ វិញ។ ប៉ុន្តែដោយមានការសង្ស័យឈ្មោះ [redacted] តូ ក៏បានខលទៅប្រាប់សមត្ថកិច្ច ហើយសមត្ថកិច្ចក៏បានចុះមកដល់កន្លែងកើតហេតុភ្លាមៗតែម្តង ។ ចំណែឈ្មោះ [redacted] សុវណ្ណារាជ វិញ ដោយសារតែឈ្មោះ [redacted] ចិន្តា ត្រូវជាបងជីដូនមួយរបស់ខ្លួន ទើបគេទៅឌុបឈ្មោះ [redacted] ចិន្តា នៅម្តុំវត្តឈើទាល តាមការពឹងពាក់ ទាំងដែលរូបគេមិនដឹងទាល់តែ

សោះថា ឈ្មោះ [redacted] ចិន្តា ទើបតែធ្វើសកម្មភាពលួចយកទ្រព្យសម្បត្តិរបស់ដើមបណ្តឹង។ នៅពេលដែលជនជាប់ចោទឈ្មោះ [redacted] សុវណ្ណារាជ ជិះម៉ូតូធ្វើដំណើរមកតាមផ្លូវមកដល់ចំណុចកើតហេតុ ក៏មានសមត្ថកិច្ចសួរនាំថា មានស្គាល់ម៉ូតូដែលដួលនៅនឹងផ្លូវឬទេ? ពេលនោះ ជនជាប់ចោទក៏បានឆ្លើយថា ស្គាល់ម្ចាស់ម៉ូតូ។ ម៉ូតូនោះគឺជារបស់ឈ្មោះ [redacted] ចិន្តា ។ ត្រង់ចំណុចនេះ រិតតែបញ្ជាក់កាន់តែច្បាស់ថា ឈ្មោះ [redacted] សុវណ្ណារាជ មិនដឹងអំពីអំពើរបស់ឈ្មោះ [redacted] ចិន្តា និងមិនបានចូលរួមលួចជាមួយឈ្មោះ សោ ចិន្តា ក្នុងនាមជាចារី សហចារី ឬអ្នកផ្តើមគំនិត ឬអ្នកសមគំនិត នោះឡើយ ពោលគឺបានសហការជាមួយសមត្ថកិច្ច ដើម្បីបញ្ជាក់ការពិតទៀតផង ។ ម្យ៉ាងវិញទៀត ផ្អែកតាមលទ្ធផលនៃការស៊ើបសួរ និងការដេញដោលក្នុងសាលសវនាការ ក្រុមប្រឹក្សាជំនុំជម្រះ យល់ឃើញថា អង្គហេតុដែលជាអំពើលួច គឺត្រូវបានកើតឡើង និងបញ្ចប់ទៅវិញដោយពុំមានវត្តមានរបស់ជនជាប់ចោទឈ្មោះ [redacted] សុវណ្ណារាជ នោះទេ។ ដូច្នេះ គប្បីក្រុមប្រឹក្សាជំនុំជម្រះពិចារណាឱ្យរួចផុតបទចោទប្រកាន់ ។

**៦. យល់ឃើញថា÷** ពុំមានភស្តុតាង និងពុំមានពិរុទ្ធភាពគ្រប់គ្រាន់ដាក់បន្ទុកលើជនជាប់ចោទឈ្មោះ [redacted] សុវណ្ណារាជ ភេទប្រុស កើតឆ្នាំ១៩៩៤ (អាយុ២៧ឆ្នាំ) ជនជាតិខ្មែរ ពីបទ÷ **អំពើលួច (មានស្ថានទម្ងន់ទោស)** ប្រព្រឹត្តនៅភូមិឈើទាល ឃុំស្វាយរមៀត ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល កាលពីថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២១ បទល្មើសដែលមានចែងតាមបញ្ញត្តិមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។ ហេតុដូច្នេះ គប្បីក្រុមប្រឹក្សាជំនុំជម្រះសម្រេចឱ្យឈ្មោះ [redacted] សុវណ្ណារាជ រួចផុតពីបទចោទប្រកាន់តាមបញ្ញត្តិមាត្រា៣៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

**៧. យល់ឃើញថា** មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់ដាក់បន្ទុកលើជនជាប់ចោទឈ្មោះ [redacted] ចិន្តា ភេទប្រុស កើតឆ្នាំ១៩៨០ (អាយុ៤១) ពីបទ÷ **អំពើលួច (មានស្ថានទម្ងន់ទោស)** ប្រព្រឹត្តនៅភូមិឈើទាល ឃុំស្វាយរមៀត ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល កាលពីថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២១ បទល្មើសដែលមានចែងតាមបញ្ញត្តិមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។

**៨. យល់ឃើញថា** អំពើល្មើស និងសកម្មភាពរបស់ជនជាប់ចោទឈ្មោះ [redacted] ចិន្តា ធ្វើឱ្យខូចសណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ ប៉ះពាល់ដល់ទ្រព្យសម្បត្តិរបស់បុគ្គលឯកជនដែលច្បាប់បានការពារ និងតម្រូវឱ្យផ្តន្ទាទោស។

**៩. យល់ឃើញថា** ពេលធ្វើសកម្មភាព ជនជាប់ចោទឈ្មោះ [redacted] ចិន្តា មានសតិ បញ្ញា ស្មារតី គ្រប់គ្រាន់ប្រព្រឹត្តអំពើល្មើសច្បាប់រហូតសម្រេចតាមបំណងរបស់ខ្លួន ហើយជានីតិជនដែលមានសមត្ថភាពពេញលេញក្នុងការទទួលខុសត្រូវនូវអំពើរបស់ខ្លួនដែលបានប្រព្រឹត្ត ។

**១០. យល់ឃើញថា** ជនជាប់ចោទឈ្មោះ [redacted] ចិន្តា ភេទប្រុស ក្រោយពីប្រព្រឹត្តបទល្មើសរួច បានរត់គេចខ្លួនមិនដឹងទៅទីណាឡើយ គប្បីតុលាការពិចារណា ចេញដីកាបង្គាប់ឱ្យចាប់ខ្លួន ស្របតាមបញ្ញត្តិមាត្រា៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។



Scanned with CamScanner

**១១. យល់ឃើញថា** ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] សីម៉ា ប្ដឹងសុំទាមទារសំណងការខូចខាត និងជំងឺចិត្ត សរុបចំនួន ១,០០០(មួយពាន់) ដុល្លារអាមេរិក ឃើញថា ការប្ដឹងតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនេះ មានភាពត្រឹមត្រូវតាមច្បាប់ គប្បីតុលាការធ្វើការពិចារណាអំពីទំហំនៃការខូចខាតជាក់ស្ដែង ស្របតាមបញ្ញត្តិមាត្រា១៣ និងមាត្រា១៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

**១២. យល់ឃើញថា** វត្ថុតាងដកហូតរួមមាន÷ ម៉ូតូម៉ាកហុងដាឌ្រីម សេ១២៥ ពណ៌ខ្មៅ ពាក់ស្លាកលេខ ភ្នំពេញ 1AW-0968 (មិនប្រក្រតី) ជាមធ្យោបាយដែលសម្រួលដល់ការប្រព្រឹត្តបទល្មើស គប្បីក្រុមប្រឹក្សាជំនុំជម្រះសម្រេចរឹបអូស ។

**១៣. យល់ឃើញថា** ម៉ូតូ០១គ្រឿង ម៉ាក សង់គូប៉េ ពណ៌ស្លាទុំ ពាក់ស្លាកលេខ កណ្ដាល 1G-0239 (មិនប្រក្រតី) ជាវត្ថុតាងដែលបានចាប់យកនៅក្នុងសំណុំរឿងនេះ មិនជាប់ពាក់ព័ន្ធនឹងអំពើល្មើស គប្បីសម្រេចប្រគល់ឱ្យម្ចាស់ដើមវិញ ស្របតាមបញ្ញត្តិមាត្រា៣៥៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

## ហេតុដូច្នេះ សម្រេចសេចក្ដី

១. ឱ្យឈ្មោះ [redacted] សុវណ្ណារាជ ភេទប្រុស កើតឆ្នាំ១៩៩៤ (អាយុ២៧ឆ្នាំ) ជនជាតិខ្មែរ រួចផុតពីបទចោទប្រកាន់ពីបទ÷ **អំពើលួច (មានស្ថានទម្ងន់ទោស)** ប្រព្រឹត្តនៅភូមិឈើទាល ឃុំស្វាយរមៀត ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល កាលពីថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២១ បទល្មើសដែលមានចែងតាមបញ្ញត្តិមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ តាមបញ្ញត្តិមាត្រា៣៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២. ផ្ដន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] ចិន្ដា ភេទប្រុស កើតឆ្នាំ១៩៨០(អាយុ៤១ឆ្នាំ) ជនជាតិខ្មែរ ដាក់ពន្ធនាគារ កំណត់រយៈពេល ០៥ (ប្រាំ) ឆ្នាំ ពីបទ÷ **អំពើលួច (មានស្ថានទម្ងន់ទោស)** ប្រព្រឹត្តនៅភូមិឈើទាល ឃុំស្វាយរមៀត ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល កាលពីថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២១ បទល្មើសដែលមានចែងតាមបញ្ញត្តិមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

៣. បង្គាប់ឱ្យចាប់ខ្លួនឈ្មោះ [redacted] ចិន្ដា ភេទប្រុស កើតឆ្នាំ១៩៨០ (អាយុ៤១ឆ្នាំ) ភេទប្រុស ជនជាតិខ្មែរ តាមបញ្ញត្តិមាត្រា៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

៤. បង្គាប់ឱ្យឈ្មោះ [redacted] ចិន្ដា ភេទប្រុស សងសំណងការខូចខាត និងជំងឺចិត្ត ចំនួន ១,០០០(មួយពាន់) ដុល្លារអាមេរិក ឱ្យទៅដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] សីម៉ា ភេទស្រី ។ ការទាមទារលើសពីនេះត្រូវច្រានចោល ។

៥. ប្រគល់ម៉ូតូ ម៉ាកសង់គូប៉េ ពណ៌ស្លាទុំ ពាក់ស្លាកលេខ កណ្ដាល 1G-0239 (មិនប្រក្រតី) ឱ្យម្ចាស់ដើមវិញ ។

**៦. រឹបអូសវត្ថុតាងរួមមាន÷**ម៉ូតូ០១ (មួយ) គ្រឿង ម៉ាកហុងដាឌ្រីម សេ ១២៥ ពណ៌ខ្មៅ ពាក់ស្លាកលេខ ភ្នំពេញ 1AW-0968 (មិនប្រក្រតី) ។



Scanned with CamScanner

សាលក្រមនេះ ជំនុំជម្រះ នៅថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២២ និងប្រកាសជាសាធារណៈ នៅថ្ងៃទី ២១ ខែមិថុនា ឆ្នាំ២០២២ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] សុវណ្ណារាជ ភេទប្រុស និងកំបាំងមុខចំពោះជនជាប់ចោទឈ្មោះ [redacted] ចិន្តា ភេទប្រុស និងដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សីម៉ា ភេទស្រី ។

បើកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

| | | | |
|---|---|---|---|
| ក្រឡាបញ្ជីសវនាការ | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
| ហត្ថលេខា និងត្រា៖ | ហត្ថលេខា និងត្រា៖ | ហត្ថលេខា និងត្រា៖ | ហត្ថលេខា និងត្រា៖ |

[redacted]

---

បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃអង្គារ ៧កើត ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

ខេត្តកណ្តាល, ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២២

ក្រឡាបញ្ជី

[redacted]

បានឃើញ

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]